# សេចក្តីណែនាំអំពីការគ្រប់គ្រងការប៉ះពាល់នឹងជំងឺ COVID-19 នៅតាមមណ្ឌលថែទាំ និងអប់រំកុមារតូច

**បច្ចុប្បន្នភាពថ្មីៗ:** (ការផ្លាស់ប្តូរត្រូវបានរំលេចដោយពណ៌លឿង)

**9/23/2021:**

- បានបន្ថែមបណ្តាញភ្ជាប់ទៅនឹងសៀវភៅណែនាំស្តីពីការថែទាំ និងអប់រំកុមារតូចទាក់ទងនឹងជំងឺ COVID-19។
- បានបន្ថែមតម្រូវការដើម្បីរាយការណ៍អំពីការសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬការទទួលមរណភាពទាំងអស់ទាក់ទងនឹងជំងឺ COVID-19 ក្នុងចំណោមសិស្ស ឬបុគ្គលិកទៅកាន់ DPH។
- បានបន្ថែមជម្រើសនៃការធ្វើចត្តាឡីស័ករយៈពេលខ្លីសម្រាប់អ្នកដែលបានប៉ះពាល់នឹងមេរោគដែលបន្តមិនមានរោគសញ្ញា និងបានប្រមូលសំណាកនៅថ្ងៃទី 5 ឬក្រោយពីនេះ បន្ទាប់ពីកាលបរិច្ឆេទនៃការប៉ះពាល់ចុងក្រោយ និងធ្វើតេស្តទទួលទួលផលអវិជ្ជមាន។
- បានបញ្ជាក់យ៉ាងច្បាស់ថា បុគ្គលិកទីតាំងថែទាំ និងអប់រំកុមារតូច (ECE) អាចវិលត្រឡប់ទៅធ្វើការវិញបន្ទាប់ពីបានបញ្ចប់រយៈពេលនៃការធ្វើចត្តាឡីស័កផ្អែកលើសេចក្តីបង្គាប់ឱ្យធ្វើចត្តាឡីស័កជាបន្ទាន់របស់សុខភាពសាធារណៈ។
- រៀបចំមាតិកាឡើងវិញសម្រាប់ភាពងាយស្រួលក្នុងការអាន និងការយល់។

ការឆ្លើយតបសុខភាពសាធារណៈដែលមានគោលដៅដើម្បីគ្រប់គ្រងការប៉ះពាល់នឹងជំងឺ COVID-19 នៅកម្រិតសហគមន៍ អាចជួយបង្កើនឥទ្ធិពលនៃការឆ្លើយតបនឹងជំងឺ COVID-19 របស់នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles (DPH) ឱ្យខ្លាំងជាងគេ។

អ្នកផ្តល់សេវាកម្មថែទាំ និងអប់រំកុមារតូច (ECE) គឺជាដៃគូសហគមន៍ដែលគួរឱ្យទុកចិត្ត ហើយដែលអាចជួយ DPH ធ្វើឱ្យឥទ្ធិពលនៃការឆ្លើយតបរបស់សុខភាពសាធារណៈប្រសើរឡើងនិងទាន់ពេលវេលា តាមរយៈការផ្តួចផ្តើមជាបន្ទាន់នៃផែនការគ្រប់គ្រងការប៉ះពាល់ (EMP) សម្រាប់ជំងឺ COVID-19។ ការអនុវត្តភ្លាមៗនៃផែនការ EMP បន្ទាប់ពីការកំណត់អត្តសញ្ញាណករណីមួយនៃជំងឺ COVID-19 នៅមជ្ឈមណ្ឌល ECE អាចធ្វើឱ្យសមត្ថភាពក្នុងការគ្រប់គ្រងការរីករាលដាលនៃជំងឺ COVID-19 បានលឿនជាងមុន និងទប់ស្កាត់កុំឲ្យករណីតែមួយនោះក្លាយជាការផ្ទុះជំងឺនៅនឹងទីតាំង។

ជំហានដើម្បីគ្រប់គ្រងការប៉ះពាល់ជំងឺ COVID-19 ចំនួន 1 2 និង 3 ករណីឡើងទៅនៅទីតាំង ECE ត្រូវបានពិពណ៌នាដូចខាងក្រោម និងសង្ខេបនៅក្នុងឧបសម្ព័ន្ធ A។ ដោយសារអ្នកផ្តល់សេវាកម្ម ECE មានកម្រិតធនធានខុសៗគ្នាសម្រាប់ការគ្រប់គ្រងការប៉ះពាល់នឹងជំងឺ COVID-19 យ៉ាងហោចណាស់ត្រូវតែរាប់បញ្ចូលជំហានដែល *ចាំបាច់* ទៅក្នុងផែនការ EMP របស់ទីតាំង។ ជំហានដែល *បានណែនាំ* បូកបញ្ចូលកត្តាដែលអាចជ្រើសរើសបានសម្រាប់ការគ្រប់គ្រងការប៉ះពាល់ ប្រសិនបើមជ្ឈមណ្ឌលមានធនធានគ្រប់គ្រាន់។

សូមកត់សម្គាល់ថា ពាក្យ "មជ្ឈមណ្ឌល" "ទីតាំង" ឬ "ទីកន្លែង"សំដៅលើអ្នកផ្តល់សេវាកម្មថែទាំកុមារទាំងអស់ដោយរាប់ បញ្ចូលទាំងអ្នកផ្តល់សេវាកម្មថែទាំកុមារតាមផ្ទះលក្ខណៈគ្រួសារ។ ពាក្យ "ករណី" ត្រូវបានប្រើដើម្បីសំដៅលើមនុស្សដែលជាប់ពាក់ព័ន្ធ ជាមួយទីតាំង ECE ដែលបានឆ្លងជំងឺ COVID-19។ នៅពេលដែលឯកសារនេះអំពាវនាវឲ្យទីតាំងបញ្ចេញសកម្មភាពសម្រាប់ករណី (ដូចជាការផ្តល់ការណែនាំ) គេគួរយល់ដឹងថា ករណីគឺជាបុគ្គលិកដែលបានប៉ះពាល់ ឬឪពុកម្តាយ (ឬអ្នកផ្តល់ការថែទាំ/អាណាព្យាបាល) របស់កុមារដែលបានប៉ះពាល់នឹងមេរោគ។ ធនធានបន្ថែមសម្រាប់មជ្ឈមណ្ឌលថែទាំ និងអប់រំកុមារតូច (ECE) អាចមាននៅក្នុង សៀវភៅណែនាំស្តីពីការថែទាំ និងអប់រំកុមារតូចទាក់ទងនឹងជំងឺ COVID-19។

## ការធ្វើផែនការគ្រប់គ្រងការប៉ះពាល់មុនពេលកំណត់អត្តសញ្ញាណជំងឺ COVID-19 ចំនួន 1 ករណីនៅទីតាំង ECE

- ❑ *ចាំបាច់៖* អ្នកទំនាក់ទំនងករណីជំងឺ COVID-19 នៃមជ្ឈមណ្ឌល ECE ដែលបានចាត់តាំងម្នាក់ នឹងដើរតួជាចំណុចទាក់ទងសម្រាប់ពិធីការសុវត្ថិភាពនៃជំងឺ COVID-19 នានា។ អ្នកដែលបានចាត់តាំង នឹងត្រូវប្រាកដថាបុគ្គលិក គ្រួសារ និងកុមារទទួលបានការអប់រំអំពីជំងឺ COVID-19 និងដើរតួជាអ្នកទំនាក់ទំនងជាមួយ DPH សម្រាប់ការចែករំលែកព័ត៌មានតាមទីកន្លែង (site-level) ដើម្បីសម្រួលដល់សកម្មភាពសុខភាពសាធារណៈ។
- ❑ *ចាំបាច់៖* ផែនការសម្រាប់កុមារ បុគ្គលិក ភ្ញៀវ និងសមាជិកគ្រួសាររបស់ទីតាំងថែទាំកុមារតូចលក្ខណៈគ្រួសារទាំងអស់ដែល (1) មានរោគសញ្ញាដូចជំងឺ COVID-19 (2) ត្រូវបានដាក់ធ្វើចត្តាឡីស័ក ដោយសារការប៉ះពាល់នៅមជ្ឈមណ្ឌល ឬ (3) កំពុងស្ថិតនៅក្នុងមជ្ឈមណ្ឌលដែលមានការស៊ើបអង្កេតសុខភាពសាធារណៈយ៉ាងសកម្ម ឱ្យមានសិទ្ធិធ្វើតេស្ត ឬធ្វើតេស្តរកជំងឺ COVID-19។ កំណត់សម្គាល់៖ បុគ្គលដែលគ្មានរោគសញ្ញា ហើយបានចាក់ថ្នាំបង្ការពេញលេញ[1] ឬអ្នកដែលបានជាសះស្បើយពីជំងឺ COVID-19 ដែលបានបញ្ជាក់ដោយមន្ទីរពិសោធន៍ក្នុងអំឡុងពេល 90 ថ្ងៃកន្លងមក មិនចាំបាច់តម្រូវឱ្យធ្វើតេស្តទេ លើកលែងតែសុខភាពសាធារណៈយល់ថាជាការចាំបាច់សម្រាប់ជាផ្នែកមួយនៃការស៊ើបអង្កេតយ៉ាងសកម្ម។
- ❑ *ចាំបាច់៖* ផែនការដើម្បីរាយការណ៍អំពីការចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ និង/ឬការស្លាប់ទាក់ទងនឹងជំងឺ COVID-19 ទាំងអស់ ក្នុងចំណោមសិស្ស ឬបុគ្គលិកទៅកាន់ DPH តាមរយៈការផ្ញើការជូនដំណឹងទៅកាន់អ៊ីម៉ែល ACDC-Education@ph.lacounty.gov។
- ❑ *បានណែនាំ៖* ទីតាំងថែទាំ និងអប់រំកុមារតូច (ECE) ដែលជ្រើសរើសអនុវត្តកម្មវិធីពិនិត្យរករោគសញ្ញាត្រូវបានណែនាំឱ្យអនុវត្តតាមសេចក្តីណែនាំរបស់ DPH ស្តីពី វិធីសម្រេចចិត្ត សម្រាប់បុគ្គលទាំងឡាយដែលមិនបានធ្វើតេស្តរកមេរោគ COVID-19 ប៉ុន្តែការពិនិត្យរករោគសញ្ញាឃើញថាវិជ្ជមានមុនពេលចូលក្នុង ឬខណៈពេលដែលនៅក្នុងទីតាំង ECE។

## ការគ្រប់គ្រងការប៉ះពាល់សម្រាប់ជំងឺ COVID-19 ចំនួន 1 ករណីនៅទីតាំង ECE

- ❑ *ចាំបាច់៖* បន្ទាប់ពីកំណត់អត្តសញ្ញាណករណីជំងឺ COVID-19 ច្បាស់លាស់ចំនួន 1 ករណីហើយ អ្នកផ្តល់សេវាកម្ម ECE បង្គាប់ឲ្យករណីនោះអនុវត្តតាមការណែនាំអំពីការដាក់ឲ្យនៅដាច់ដោយឡែកនៅផ្ទះសម្រាប់ជំងឺ COVID-19 (ph.lacounty.gov/covidisolation)។ សម្គាល់៖ ករណីជំងឺ COVID-19 ច្បាស់លាស់ គឺជាបុគ្គលដែលត្រូវបានបញ្ជាក់ក្រោយពីបានធ្វើតេស្តរកមេរោគ COVID-19 ថាវិជ្ជមាន។
- ❑ *ចាំបាច់៖* អ្នកផ្តល់សេវាកម្ម ECE ជម្រាបជូនដល់ករណីនេះថា DPH នឹងទាក់ទងទៅករណីដោយផ្ទាល់តាមរយៈកម្មវិធីស៊ើបអង្កេតករណីនិងការទំនាក់ទំនងរបស់ DPH (DPH Case and Contact Investigation Program) ដើម្បីប្រមូលព័ត៌មានបន្ថែម និងចេញសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាលសម្រាប់ការដាក់ករណីឲ្យនៅដាច់ដោយឡែក។
- ❑ *ចាំបាច់៖* អ្នកទំនាក់ទំនងករណីជំងឺ COVID-19 នៃមជ្ឈមណ្ឌល ECE ត្រូវជូនដំណឹងទៅ DPH អំពី (1) បុគ្គលណាដែលបានបញ្ជាក់ថាមានជំងឺ COVID-19 ដែលស្ថិតនៅទីតាំងនោះនៅពេលណាមួយក្នុងរយៈពេល 14 ថ្ងៃមុនកាលបរិច្ឆេទចាប់ផ្តើមមានជំងឺ និង (2) បុគ្គលណាដែលមានការប៉ះពាល់ជាមួយអ្នកផ្ទុកមេរោគ ក្នុងអំឡុងពេលដែលអាចចម្លងជំងឺនេះបាន។ កាលបរិច្ឆេទចាប់ផ្តើមមានជំងឺ គឺជាកាលបរិច្ឆេទដំបូងនៃរោគសញ្ញាជំងឺ COVID-19 ឬកាលបរិច្ឆេទនៃការធ្វើតេស្តរកមេរោគ COVID-19 សូមយកថ្ងៃមួយណាក៏បានដែលកើតឡើងមុន។
  - ករណីត្រូវបានចាត់ទុកថាអាចចម្លងមេរោគចាប់ពី 2 ថ្ងៃ មុនពេលពួកគេចេញរោគសញ្ញាដំបូង រហូតដល់ពេលដែលពួកគេលែងតម្រូវឲ្យដាក់ខ្លួនឲ្យនៅដាច់ដោយឡែក (ឧ. មិនមានអការៈគ្រុនក្តៅរយៈពេលយ៉ាងតិច 24 ម៉ោង ដោយមិនប្រើថ្នាំបញ្ចុះកម្តៅ ហើយរោគសញ្ញាផ្សេងៗបានធូរស្បើយ និងយ៉ាងតិចបំផុត 10 ថ្ងៃបានកន្លងផុតទៅ ចាប់តាំងពីពេលចេញរោគសញ្ញាដំបូង)។ បុគ្គលដែលបាន

[1] ការចាក់ថ្នាំបង្ការពេញលេញត្រូវបានកំណត់ថា ចាប់ពីរសប្តាហ៍ឡើងទៅ ចាប់តាំងពីទទួលបានដូសទី 2 នៃប្រភេទថ្នាំបង្ការដែលមានពីរដូស ឬពីរសប្តាហ៍បានកន្លងផុត ចាប់តាំងពីទទួលថ្នាំបង្ការដែលមានតែមួយដូស រួចរាល់មក។

ធ្វើតេស្តជំងឺ COVID-19 ថាវិជ្ជមាន ប៉ុន្តែគ្មានរោគសញ្ញា ត្រូវបានចាត់ទុកថាអាចចម្លងមេរោគចាប់ពី 2 ថ្ងៃមុនពេលពួកគេធ្វើតេស្តរហូតដល់ 10 ថ្ងៃបន្ទាប់ពីការធ្វើតេស្តរបស់ពួកគេ។ បុគ្គលម្នាក់ត្រូវបានចាត់ទុកថាបានប៉ះពាល់នឹងករណីណាមួយក្នុងអំឡុងរយៈពេលដែលអាចចម្លងជំងឺ ប្រសិនបើត្រូវតាមចំណុចយ៉ាងតិចមួយក្នុងចំណោមលក្ខខ័ណ្ឌខាងក្រោម៖

- ស្ថិតក្នុងគម្លាត 6 ហ្វីតពីមនុស្សផ្ទុកជំងឺរយៈពេលសរុប 15 នាទីឬលើសពីនេះក្នុងរយៈពេល 24 ម៉ោង
- បានប៉ះពាល់ជាមួយសារធាតុរាវនៃរាងកាយ និង/ឬសារធាតុបញ្ចេញរបស់បុគ្គលដែលបានបញ្ជាក់ថាមាន ជំងឺ COVID-19 ដោយមិនបានការពារ (ឧ. ត្រូវបានក្អក ឬកណ្តាស់ដាក់ ការប្រើប្រដាប់ប្រដា បរិភោគអាហាររួមគ្នា ឬជាប់ទឹកមាត់គ្នា ឬផ្តល់ការថែទាំដោយមិនបានប្រើឧបករណ៍ការពារត្រឹមត្រូវ)។.
- ចំណាំ៖ ការប៉ះពាល់នឹងមេរោគទាំងនេះនឹងត្រូវត្រួតពិនិត្យឡើងវិញដោយសុខភាពសាធារណៈ ដើម្បីបញ្ជាក់ថា តើបុគ្គលណាដែលតម្រូវឱ្យធ្វើចត្តាឡីស័ក។

- ការធ្វើរបាយការណ៍តាមអនឡាញដែលមានសុវត្ថិភាព គឺជាវិធីសាស្ត្រដ៏ល្អសម្រាប់ជូនដំណឹងដល់ DPH ចំពោះការប៉ះពាល់ករណី COVID-19 ហើយអាចធ្វើបាននៅលើកុំព្យូទ័រ ឬទូរស័ព្ទចល័តដែលអាចចូលទៅកាន់កម្មវិធីបណ្តាញដែលមានសុវត្ថិភាពតាមរយៈ៖ http://www.redcap.link/lacdph.educationsector.covidreport ។ ប្រសិនបើការរាយការណ៍តាមអនឡាញមិនអាចធ្វើបានទេ នោះការរាយការណ៍អាចធ្វើឡើងដោយផ្ទាល់តាមរយៈការទាញយក និងបំពេញ តារាងបញ្ជីករណីនិងអ្នកដែលមានទំនាក់ទំនងនឹងជំងឺ COVID-19 សម្រាប់វិស័យអប់រំ ហើយផ្ញើទៅACDC-Education@ph.lacounty.gov ។ រាល់ការជូនដំណឹងអំពីករណីទាំងអស់គួរតែត្រូវបានដាក់បញ្ជូនក្នុងរយៈពេល 1 ថ្ងៃធ្វើការ បន្ទាប់ពីបានទទួលដំណឹងអំពីករណីនេះ។

❑ *ចាំបាច់៖* បុគ្គលណាដែលត្រូវបានកំណត់អត្តសញ្ញាណថា បានប៉ះពាល់ជាមួយករណីនៅនឹងទីតាំង ត្រូវបានជូនដំណឹងដោយអ្នកផ្តល់សេវាកម្ម ECE តាមរយៈលិខិត ឬមធ្យោបាយទំនាក់ទំនងផ្សេងៗទៀត។ គំរូលិខិតជូនដំណឹងអំពីការប៉ះពាល់គឺមាននៅ៖ គំរូលិខិតជូនដំណឹងសម្រាប់មណ្ឌលថែទាំ និងអប់រំកុមារតូច ទាក់ទងនឹងជំងឺ COVID-19 (គំរូលិខិតទី 1)។ ការជូនដំណឹងអំពីការប៉ះពាល់គួររាប់បញ្ចូលចំណុចដូចខាងក្រោម៖

- DPH នឹងទាក់ទងមនុស្សណាដែលបានប៉ះពាល់នឹងមេរោគនៅទីតាំងនោះដែលស្របទៅនឹងតម្រូវការឱ្យធ្វើចត្តាឡីស័ក តាមរយៈកម្មវិធីស៊ើបអង្កេតករណី និងអ្នកដែលមានទំនាក់ទំនងរបស់ DPH ដើម្បីប្រមូលព័ត៌មានបន្ថែម និងចេញជូននូវសេចក្តីបង្គាប់សម្រាប់ការធ្វើចត្តាឡីស័ករបស់មន្ត្រីសុខាភិបាល។
- បុគ្គលិកដែលមានការប៉ះពាល់នៅបរិវេណទីតាំង គួរតែអនុវត្តតាមសេចក្តីណែនាំដូចដែលមានចែងនៅក្នុង បទដ្ឋានបណ្តោះអាសន្នបន្ទាន់ នៃការបង្ការជំងឺ COVID-19 (ETS) របស់ Cal/OSHA។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើរយៈពេលនៃការចត្តាឡីស័ករបស់បុគ្គលិកបញ្ចប់មុនពេលពួកគេបំពេញតាម លក្ខខ័ណ្ឌសម្រាប់ការវិលត្រឡប់ទៅធ្វើការវិញរបស់ Cal/OSHA ពួកគេអាចវិលត្រឡប់ទៅកន្លែងធ្វើការវិញ ដរាបណាពួកគេបានបញ្ចប់ការធ្វើចត្តាឡីស័កដោយមិនមានបញ្ហា ដោយផ្អែកលើ សេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាលសម្រាប់ការធ្វើចត្តាឡីស័ក។ សេចក្តីសង្ខេបនៃតម្រូវការត្រូវបានផ្តល់ជូននៅក្នុងឯកសារណែនាំរបស់សុខភាពសាធារណៈស្តីពី ការឆ្លើយតបទៅនឹងជំងឺ COVID-19 នៅកន្លែងធ្វើការ។
- បុគ្គលនានាដែលមានការប៉ះពាល់ជាមួយករណីនៅទីតាំងនោះ គួរធ្វើតេស្តរកជំងឺ COVID-19 មិនថាពួកគេមានរោគសញ្ញាឬក៏អត់នោះទេ ហើយជូនដំណឹងដល់អ្នកផ្តល់សេវាកម្ម ECE អំពីលទ្ធផលតេស្ត។ នេះនឹងកំណត់ពីកម្រិតរីករាលដាលនៃជំងឺនៅទីតាំង ECE និងដើរតួជាមូលដ្ឋានសម្រាប់វិធានការណ៍គ្រប់គ្រងបន្ថែម។ ធនធានសម្រាប់ធ្វើតេស្តរួមមាន សេវាកម្មសុខភាពបុគ្គលិក ឬសេវាកម្មសុខភាពការងារ អ្នកផ្តល់សេវាកម្មថែទាំសុខភាពផ្ទាល់ខ្លួន ទីតាំងធ្វើតេស្តនានានៅខោនធីនិងទីក្រុង LA មាននៅ៖ covid19. lacounty.gov/testing ព្រមទាំងទីតាំងធ្វើតេស្តតាមសហគមន៍ (មណ្ឌលសុខភាព និងឱសថស្ថានក្នុងតំបន់)។ បុគ្គលដែលត្រូវការជំនួយក្នុងការស្វែងរកអ្នកផ្តល់សេវាកម្មថែទាំសុខភាព អាចទូរស័ព្ទទៅខ្សែទូរស័ព្ទព័ត៌មានរបស់ខោនធី Los Angeles តាមរយៈលេខ 2-1-1 ដែលអាចទាក់ទងបាន 24 ម៉ោងក្នុងមួយសប្តាហ៍។ មនុស្សដែលបានប៉ះពាល់នឹងមេរោគ

ដែលមិនត្រូវបានលើកលែងពីការធ្វើចត្តាឡីស័ក (សូមមើលការលើកលែងខាងក្រោម) ត្រូវតែធ្វើចត្តាឡីស័កដោយខ្លួនឯង (ស្នាក់នៅតែផ្ទះរបស់ពួកគេ ឬលំនៅស្ថានផ្សេងទៀត ដាច់ដោយឡែកពីអ្នកដទៃ) និងតាមដានរោគសញ្ញាដូចមានចែងនៅក្នុង សេចក្តីណែនាំអំពីកាធ្វើចត្តាឡីស័ក និងសេចក្តីណែនាំសម្រាប់បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធ។ ដរាបណាពួកគេមិនកើតមានរោគសញ្ញានៃជំងឺ COVID-19 ពួកគេអាចបញ្ចប់ពីការធ្វើចត្តាឡីស័កតាមរយៈចំណុចមួយណាក៏បាន៖

- បន្ទាប់ពី 10 ថ្ងៃពេញបានកន្លងផុតពីការប៉ះពាល់ចុងក្រោយរបស់ពួកគេទៅនឹងករណីដែលអាចចម្លងមេរោគបាន (ដូចបានកំណត់ខាងលើ)។ សកម្មភាពផ្សេងៗអាចបន្តចាប់ផ្តើមនៅថ្ងៃទី 11។ ពួកគេត្រូវតែបន្តតាមដានសុខភាពរបស់ពួកគេ និងប្រកាន់ខ្ជាប់នូវការប្រុងប្រយ័ត្នក្នុងការបង្ការជំងឺ COVID-19 រហូតដល់ថ្ងៃទី 14។
- បន្ទាប់ពី 7 ថ្ងៃពេញបានកន្លងផុតពីការប៉ះពាល់ចុងក្រោយរបស់ពួកគេទៅនឹងករណីដែលអាចចម្លងមេរោគបាន ប្រសិនបើពួកគេទទួលលទ្ធផលធ្វើតេស្តរកមេរោគអវិជ្ជមាន ពីសំណាកដែលប្រមូលបាននៅថ្ងៃទី 5 ឬក្រោយមកទៀតបន្ទាប់ពីកាលបរិច្ឆេទនៃការប៉ះពាល់ចុងក្រោយទៅនឹងករណីនេះ។ សកម្មភាពផ្សេងៗអាចបន្តចាប់ផ្តើមនៅថ្ងៃទី 8។ ពួកគេត្រូវតែបន្តតាមដានសុខភាពរបស់ពួកគេ និងប្រកាន់ខ្ជាប់នូវការប្រុងប្រយ័ត្នក្នុងការបង្ការជំងឺ COVID-19 រហូតដល់ថ្ងៃទី 14។ សូមចំណាំថា ការធ្វើតេស្តនេះត្រូវតែជាការធ្វើតេស្តជំងឺ COVID-19 ដែលទទួលស្គាល់ដោយរដ្ឋបាលចំណីអាហារ និងឱសថ (FDA) រួមមានការធ្វើតេស្តរកហ្សែនមេរោគ ឬការធ្វើតេស្តពង្រីកអាស៊ីដនុយក្លេអ៊ីច [(NAAT) ដូចជាតេស្តរកទម្រង់មេរោគ (PCR)] ឬតេស្តរកសារធាតុដែលបញ្ចូលក្នុងខ្លួនដើម្បីបង្កើតភាពស៊ាំ (Antigen test) ដែលសំណាកត្រូវបានប្រមូល និងធ្វើតេស្តឡើងនៅក្នុងកន្លែងថែទាំសុខភាព ឬកន្លែងធ្វើតេស្តដែលមានការទទួលស្គាល់ត្រឹមត្រូវ។

- បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធខាងក្រោមត្រូវបានលើកលែងពីការធ្វើចត្តាឡីស័ក ប្រសិនបើពួកគេនៅតែមិនមានរោគសញ្ញា៖
  - បុគ្គលណាដែលបាន ចាក់ថ្នាំបង្ការពេញលេញ។
  - បុគ្គលណាដែលបានជាសះស្បើយពីជំងឺ COVID-19 ដែលបានបញ្ជាក់ដោយមន្ទីរពិសោធន៍ក្នុងអំឡុងពេល 90 ថ្ងៃចុងក្រោយ។

ទោះបីជាពួកគេមិនចាំបាច់ធ្វើចត្តាឡីស័កក៏ដោយ ពួកគេត្រូវតែតាមដានរោគសញ្ញានានា ហើយប្រកាន់ខ្ជាប់យ៉ាងតឹងរឹងនូវការប្រុងប្រយ័ត្នចំពោះជំងឺ COVID-19 រយៈពេល 14 ថ្ងៃចាប់ពីថ្ងៃនៃការប៉ះពាល់ចុងក្រោយរបស់ពួកគេ។ មានការណែនាំឱ្យអ្នកដែលបានចាក់ថ្នាំបង្ការពេញលេញធ្វើតេស្តរកមេរោគអំឡុងពេល 3 ទៅ 5 ថ្ងៃបន្ទាប់ពីការប៉ះពាល់ចុងក្រោយរបស់ពួកគេ។ ការធ្វើតេស្តមិនត្រូវបានណែនាំសម្រាប់អ្នកដែលទើបតែជាសះស្បើយពីជំងឺ COVID-19 នោះទេ។ សូមមើល សេចក្តីណែនាំអំពីការធ្វើចត្តាឡីស័ក និងសេចក្តីណែនាំសម្រាប់បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធ។

❑ *បានណែនាំ៖* អ្នកផ្តល់សេវាកម្ម ECE នឹងកំណត់ថា តើចាំបាច់ត្រូវធ្វើការជូនដំណឹងបន្ថែមដែរឬទេ ដល់សហគមន៍មជ្ឈមណ្ឌល ECE ដែលទូលំទូលាយ អំពីការប៉ះពាល់នៅនឹងទីតាំង និងការប្រុងប្រយ័ត្នដែលកំពុងត្រូវបានអនុវត្តដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺ COVID-19។ គំរូលិខិតជូនដំណឹងទូទៅគឺមាននៅ៖ គំរូលិខិតជូនដំណឹងសម្រាប់មណ្ឌលថែទាំ និងអប់រំកុមារតូចទាក់ទងនឹងជំងឺ COVID-19 (គំរូលិខិតទី 2)។

## ការគ្រប់គ្រងការប៉ះពាល់សម្រាប់ករណីជំងឺ COVID-19 ចំនួន 2 នៅទីតាំង ECE ក្នុងអំឡុងពេល 14 ថ្ងៃ

❑ *ចាំបាច់៖* បន្ទាប់ពីកំណត់អត្តសញ្ញាណករណីច្បាស់លាស់ចំនួន 2 ករណីក្នុងអំឡុងពេល 14 ថ្ងៃ អ្នកផ្តល់សេវាកម្ម ECE អនុវត្តតាមជំហានដែល *ចាំបាច់* សម្រាប់ករណីច្បាស់លាស់ចំនួន 1 ករណី។

❑ *ចាំបាច់៖* អ្នកផ្តល់សេវាកម្ម ECE ពិគ្រោះជាមួយសុខភាពសាធារណៈដើម្បីធ្វើការកំណត់ថា តើករណីច្បាស់លាស់ទាំង 2 មានការទាក់ទងនឹងការរីករាលដាលនៃជំងឺដែរឬទេ នេះមានន័យថាបុគ្គលដែលរងការប៉ះពាល់ទាំងពីរមានវត្តមាននៅទីកន្លែងដូចគ្នា ក្នុងពេលតែមួយ ខណៈពេលអាចចម្លងមេរោគបាន។* អ្នកផ្តល់សេវាកម្ម ECE គួរតែទាក់ទងទៅកាន់ DPH សម្រាប់ស្វែងរកជំនួយក្នុងការកំណត់ថា តើករណីឆ្លង

នានាទាក់ទងនឹងការរីករាលដាលនៃជំងឺឬទេ តាមរយៈការផ្ញើអ៊ីម៉ែលទៅ ACDC-Education@ph.lacounty.gov។

*ករណីត្រូវបានគេចាត់ទុកថាអាចចម្លងមេរោគចាប់ពី 2 ថ្ងៃមុនពេលចេញរោគសញ្ញាដំបូង រហូតដល់ពេលដែលពួកគេលែងតម្រូវឲ្យដាក់ខ្លួនឲ្យនៅដាច់ដោយឡែក (ឧ. មិនមានអការៈគ្រុនក្តៅរយៈពេលយ៉ាងតិច 24 ម៉ោង ដោយមិនប្រើថ្នាំបញ្ចុះកម្តៅ ហើយរោគសញ្ញាបានធូរស្បើយ និងយ៉ាងតិចបំផុត 10 ថ្ងៃបានកន្លងផុតចាប់តាំងពីពេលចេញរោគសញ្ញាដំបូង)។ បុគ្គលដែលបានធ្វើតេស្តជំងឺ COVID-19 ថាវិជ្ជមាន ប៉ុន្តែគ្មានរោគសញ្ញា ត្រូវបានចាត់ទុកថាអាចចម្លងមេរោគចាប់ពី 2 ថ្ងៃមុនពេលពួកគេធ្វើតេស្តរហូតដល់ 10 ថ្ងៃបន្ទាប់ពីការធ្វើតេស្តរបស់ពួកគេ។*

- ការកំណត់ពីការទាក់ទងនឹងការរីករាលដាលនៃជំងឺរវាងករណី អាចនឹងតម្រូវឲ្យមានការស៊ើបអង្កេតបន្ថែម ដើម្បីវាយតម្លៃប្រវត្តិនៃការប៉ះពាល់ និងកំណត់ទីកន្លែង និងមនុស្សដែលអាចមានទាំងអស់ ហើយដែលអាចត្រូវបានប៉ះពាល់ជាមួយករណី ខណៈពេលកំពុងអាចចម្លងមេរោគបាននៅទីតាំងនោះ។ សូមកត់សម្គាល់ថា៖ ករណីដែលទាក់ទងនឹងការរីករាលដាលនៃជំងឺ រួមមានបុគ្គលមានទំនាក់ទំនងទៅវិញទៅមកដែលអាចកំណត់បាន ដូចជាការស្ថិតនៅកន្លែងរួមគ្នា (ឧ. នៅក្នុងថ្នាក់រៀន ការិយាល័យ ឬការជួបជុំគ្នាជាដើម) ដែលបង្ហាញថា ការរីករាលដាលនៃជំងឺដែលមានទំនាក់ទំនងគ្នានៅក្នុងកន្លែងនោះអាចកើតឡើងបានច្រើន ហើយមិនមែនជាការឆ្លងយូរៗម្តងក្នុងសហគមន៍ដែលធំទូលាយនោះទេ។ ប្រសិនបើការទាក់ទងនឹងការរីករាលដាលនៃជំងឺកើតមានឡើង DPH នឹងផ្តល់ការណែនាំទៅអ្នកផ្តល់សេវាកម្ម ECE អំពីជំហានសំខាន់ៗដែលត្រូវធ្វើ និងការផ្សព្វផ្សាយនានា ដល់កុមារ ឪពុកម្តាយ/អ្នកផ្តល់ការថែទាំ/អាណាព្យាបាល និងបុគ្គលិកអំពីការប្រុងប្រយ័ត្នដែលត្រូវធ្វើ ដើម្បីទប់ស្កាត់ការរីករាលដាលបន្ថែមទៀតនៅទីកន្លែង ដោយរាប់បញ្ចូលទាំងការអនុវត្តការអន្តរាគមន៍ជាក់លាក់សម្រាប់ការគ្រប់គ្រងការឆ្លងមេរោគផងដែរ។

## ការគ្រប់គ្រងការប៉ះពាល់សម្រាប់ករណីជំងឺ COVID-19 ចំនួន ≥ 3 នៅទីតាំង ECE ក្នុងរយៈពេល 14 ថ្ងៃ

❑ *ចាំបាច់៖* ប្រសិនបើអ្នកផ្តល់សេវាកម្ម ECE បានកំណត់អត្តសញ្ញាណនៃការឆ្លងជាចង្កោមដែលច្បាស់លាស់ចំនួន 3 ករណីឬច្រើនជាងនេះ ក្នុងរយៈពេល 14 ថ្ងៃ អ្នកផ្តល់សេវាកម្ម ECE គួរអនុវត្តតាមជំហានដូចខាងក្រោម៖

- រាយការណ៍ពីចង្កោមជាបន្ទាន់ទៅកាន់ DPH។ ការរាយការណ៍តាមអនឡាញដែលមានសុវត្ថិភាពគឺជាវិធីសាស្ត្រដ៏ល្អសម្រាប់ជូនដំណឹងដល់ DPH និងអាចធ្វើបាននៅលើកុំព្យូទ័រ ឬទូរស័ព្ទចល័តដែលអាចចូលប្រើកម្មវិធីបណ្តាញដែលមានសុវត្ថិភាពតាមរយៈ៖ http://www.redcap.link/lacdph.educationsector.covidreport។ ប្រសិនបើមិនអាចធ្វើការរាយការណ៍តាមអនឡាញបានទេនោះ ការរាយការណ៍អាចធ្វើបានដោយផ្ទាល់តាមរយៈទាញយក និងបំពេញ តារាងបញ្ជីករណី និងអ្នកដែលមានទំនាក់ទំនងនឹងជំងឺ COVID-19 សម្រាប់វិស័យអប់រំ និងផ្ញើទៅកាន់ ACDC-Education@ph.lacounty.gov។
- DPH នឹងពិនិត្យមើលព័ត៌មានដែលបានបញ្ជូនទៅដើម្បីកំណត់ថា តើបានស្របតាមលក្ខខ័ណ្ឌនៃការផ្ទុះជំងឺដែលបានពិពណ៌នាខាងក្រោមឬទេ ហើយជូនដំណឹងដល់អ្នកផ្តល់សេវាកម្ម ECE ក្នុងរយៈពេល 1 ថ្ងៃធ្វើការដើម្បីណែនាំអំពីជំហានបន្ទាប់។
- លក្ខខ័ណ្ឌនៃការផ្ទុះជំងឺ៖ យ៉ាងហោចណាស់មានករណីច្បាស់លាស់ចំនួន 3 ករណី ក្នុងរយៈពេល 14 ថ្ងៃនៅក្នុងក្រុមដែលបានបញ្ជាក់* នៅតាមទីតាំង ECEដែលសមាជិកដែលទាក់ទងនឹងការរីករាលដាលនៃជំងឺ មិនស្នាក់នៅក្នុងគ្រួសារតែមួយ និងមិនមានទំនាក់ទំនងជិតស្និទ្ធនឹងគ្នានៅខាងក្រៅនៃបរិវេណសាលារៀន។
  **ក្រុមដែលបានបញ្ជាក់រាប់បញ្ចូលបុគ្គលនានាដែលមានភាពជាសមាជិកទូទៅរួមគ្នា (ឧ. ថ្នាក់រៀន ព្រឹត្តិការណ៍ ECE ឬសកម្មភាពក្រៅកម្មវិធីសិក្សា ECE តែមួយ)។*
  - ប្រសិនបើមិនស្របតាមលក្ខខ័ណ្ឌនៃការផ្ទុះជំងឺទេ DPH នឹងផ្តល់ការណែនាំដល់អ្នកផ្តល់សេវាកម្ម ECE ដើម្បីបន្តការគ្រប់គ្រងការប៉ះពាល់តាមទម្លាប់។
  - ប្រសិនបើស្របតាមលក្ខខ័ណ្ឌនៃការផ្ទុះជំងឺមែន នោះការស៊ើបអង្កេតអំពីការផ្ទុះជំងឺ

របស់ DPH ត្រូវបានដាក់ឲ្យដំណើរការ ហើយអ្នកស៊ើបអង្កេតសុខភាពសាធារណៈនឹងទាក់ទងដោយផ្ទាល់ជាមួយអ្នកផ្តល់សេវាកម្ម ECE ដើម្បីសម្របសម្រួលការឆ្លើយតបនឹងការរីករាលដាលនេះ។

### ឧបសម្ព័ន្ធ A៖ ជំហានដើម្បីគ្រប់គ្រងការប៉ះពាល់នឹងករណីជំងឺ COVID-19 នៅទីតាំង ECE មួយ

| | |
|---|---|
| **1 ករណី** | 1) *ចាំបាច់៖* អ្នកផ្តល់សេវាកម្ម ECE ណែនាំឲ្យករណីនេះអនុវត្តតាមសេចក្តីណែនាំអំពីការដាក់ឲ្យនៅដាច់ដោយឡែកនៅផ្ទះ។<br>2) *ចាំបាច់៖* អ្នកផ្តល់សេវាកម្ម ECE ជម្រាបជូនដល់ករណីថា នាយកដ្ឋានសុខភាពសាធារណៈ (DPH) នឹងទាក់ទងករណីដោយផ្ទាល់ដើម្បីប្រមូលព័ត៌មានបន្ថែម និងចេញសេចក្តីបង្គាប់របស់មន្រ្តីសុខាភិបាលសម្រាប់ការដាក់ករណីឲ្យនៅដាច់ដោយឡែក។<br>3) *ចាំបាច់៖* អ្នកផ្តល់សេវាកម្ម ECE សហការជាមួយ DPH ដើម្បីកំណត់អត្តសញ្ញាណអ្នកដែលមានទំនាក់ទំនងនានានៅមជ្ឈមណ្ឌល ECE។<br>4) *ចាំបាច់៖* អ្នកផ្តល់សេវាកម្ម ECE ជូនដំណឹង* ដល់អ្នកមានទំនាក់ទំនងនៅ ECE អំពីការប៉ះពាល់នឹងមេរោគ។ អ្នកមានទំនាក់ទំនងនៅ ECE ត្រូវបានណែនាំឱ្យធ្វើចត្តាឡីស័កនៅផ្ទះ ហើយធ្វើតេស្តរកជំងឺ COVID-19 ដោយសារការប៉ះពាល់នឹងមេរោគរបស់ពួកគេ។<br>5) *ចាំបាច់៖* អ្នកផ្តល់សេវាកម្ម ECE ជម្រាបជូនដល់អ្នកមានទំនាក់ទំនងនៅមជ្ឈមណ្ឌល ECE ថា DPH នឹងទាក់ទងបន្តដើម្បីប្រមូលព័ត៌មានបន្ថែម និងចេញសេចក្តីបង្គាប់របស់មន្រ្តីសុខាភិបាលសម្រាប់ការធ្វើចត្តាឡីស័ក។<br>6) *ចាំបាច់៖* អ្នកផ្តល់សេវាកម្ម ECE បញ្ជូនរបាយការណ៍ទៅ DPH ក្នុងរយៈពេល 1 ថ្ងៃធ្វើការ ដោយមានព័ត៌មានអំពីករណីច្បាស់លាស់ និងអ្នកដែលបានប៉ះពាល់ជាមួយនឹងករណីនៅទីតាំងនោះ។<br>7) *បានណែនាំ៖* អ្នកផ្តល់សេវាកម្ម ECE ផ្ញើការជូនដំណឹងទូទៅ* ដើម្បីជម្រាបដល់សហគមន៍មជ្ឈមណ្ឌល ECE អំពីការប៉ះពាល់នៅទីកន្លែង និងការប្រុងប្រយ័ត្នដែលកំពុងត្រូវបានអនុវត្តដើម្បីទប់ស្កាត់ការរីករាលដាល។ |
| **2 ករណី** | 1) *ចាំបាច់៖* អនុវត្តតាមជំហានចាំបាច់នានាសម្រាប់ករណីច្បាស់លាស់ចំនួន 1។<br>2) *បានណែនាំ៖* ប្រសិនបើករណី 2 នេះកើតឡើងក្នុងអំឡុងពេល 14 ថ្ងៃពីគ្នា អ្នកផ្តល់សេវាកម្ម ECE សហការជាមួយ DPH ដើម្បីកំណត់ថា តើករណីទាំងនេះមានការទំនាក់ទំនងនឹងការរាលដាលនៃជំងឺឬទេ។ ប្រសិនបើ ការទាក់ទងនឹងការរីករាលដាលនៃជំងឺកើតមាន៖ ទីតាំង ECE នឹងអនុវត្តវិធានការណ៍គ្រប់គ្រងជំងឺឆ្លងបន្ថែមទៀត។ |
| **3+ ករណី** | 1) *ចាំបាច់៖* ប្រសិនបើមានចង្កោមករណីចំនួន 3 ឬច្រើនជាងនេះ បានកើតឡើងក្នុងរយៈពេល 14 ថ្ងៃពីគ្នា អ្នក ផ្តល់សេវាកម្ម ECE ជូនដំណឹងដល់ DPH ជាបន្ទាន់តាមរយៈការរាយការណ៍តាមអនឡាញ៖ http://www.redcap.link/lacdph.educationsector.covidreport។<br>2) *ចាំបាច់៖* DPH កំណត់ថា តើបានស្របនឹងល័ក្ខខ័ណ្ឌនៃការផ្ទុះជំងឺឬទេ។ ប្រសិនបើស្របតាមល័ក្ខខ័ណ្ឌនៃការផ្ទុះជំងឺមែន ការស៊ើបអង្កេតអំពីការផ្ទុះជំងឺរបស់ DPH ត្រូវបានដាក់ឱ្យដំណើរការ ហើយអ្នកស៊ើបអង្កេតសុខភាពសាធារណៈ នឹងទាក់ទងទៅទីតាំង ECE ដើម្បីសម្របសម្រួលការស៊ើបអង្កេតអំពីការផ្ទុះជំងឺនេះ។ |